From
the People of Japan

WFP
World Food
Programme

# សេចក្តីប្រកាសព័ត៌មាន

## ថ្ងៃទី ២១និង២២ ខែឧសភា ឆ្នាំ២០២១

### គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្ថានទូតជប៉ុន និង កម្មវិធីស្បៀងអាហារពិភពលោក (WFP) ប្រគល់មជ្ឈមណ្ឌលជម្លៀសសុវត្ថិភាព ដែលទើបនឹងសាងសង់រួចថ្មី ចំនួន៦កន្លែង ដល់សហគមន៍មូលដ្ឋាន

**ថ្ងៃទី២១និង២២ ខែឧសភា ខេត្តពោធិ៍សាត់និងកំពង់ធំ៖** ជាកិច្ចបញ្ចប់ការសាងសង់មជ្ឈមណ្ឌលជម្លៀសសុវត្ថិភាពចំនួន៦ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់នៅក្នុងសហគមន៍ងាយរងគ្រោះ ស្ថានទូតជប៉ុន និងកម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ (WFP) បានសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម.) ដើម្បីប្រគល់មជ្ឈមណ្ឌលទាំងនេះជាផ្លូវការជូនទៅកាន់សហគមន៍មូលដ្ឋានក្នុងខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិសាត់ មុនពេលរដូវវស្សាចាប់ផ្តើម។

មជ្ឈមណ្ឌលជម្លៀសសុវត្ថិភាពត្រូវបានសាងសង់ឡើងស្របតាមបទដ្ឋានអន្តរជាតិ និងមានសាលធំទូលាយ ផ្ទះបាយ កន្លែងបោកខោអាវ បន្ទប់ស្តុកទំនិញ បន្ទប់ទឹក កន្លែងលាងដៃ ទីជម្រកសម្រាប់សត្វ និងទីវាលធំទូលាយ។ នៅតាមមជ្ឈមណ្ឌលនីមួយៗមានបំពាក់ទៅដោយប្រព័ន្ធផ្គត់ផ្គង់ទឹក (អណ្តូង អាងស្តុកទឹក និងធុងទឹក) ប្រព័ន្ធអគ្គិសនី (ម៉ាស៊ីនភ្លើង ប្រព័ន្ធថាមពលព្រះអាទិត្យ) និងប្រព័ន្ធការពាររន្ទះ។

មជ្ឈមណ្ឌលជម្លៀសទាំងនេះ អាចដាក់មនុស្សបាន ពី២០០០ ទៅ៣០០០នាក់ ហើយនេះគឺជាការបង្ហាញនូវការប្តេជ្ញានិងយកចិត្តទុកដាក់ជាបន្តបន្ទាប់របស់ជប៉ុនដែលមានជាយូរមកហើយចំពោះប្រជាជនកម្ពុជា។ មជ្ឈមណ្ឌលទាំងនេះមានមុខងារចំនួនពីរគឺសម្រាប់ជម្លៀសប្រជាជនទៅកាន់ទីសុវត្ថិភាពក្នុងករណីមានព្យុះនិងទឹកជំនន់ក្នុងរដូវវស្សា និងជាទីកន្លែងប្រើប្រាស់ទូទៅក្នុងគោលបំណងចម្រុះ។ ថ្មីៗនេះមជ្ឈមណ្ឌលនេះ

ត្រូវបានប្រើប្រាស់ជាកន្លែងចាក់វ៉ាក់សាំងការពារកូវីដ-១៩ និងជាមណ្ឌលចត្តាឡីស័កផងដែរ។

ឯកឧត្តម **Karimata Atsushi** រដ្ឋមន្ត្រី និងជាអនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុនប្រចាំនៅកម្ពុជាមានប្រសាសន៍ថា "ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមនៅក្នុងពិធីប្រគល់ជូននេះ។ រដ្ឋាភិបាលនិងប្រជាជនជប៉ុនមានមោទនភាពក្នុងការចូលរួមចំណែកកសាងភាពធន់និងរឹងមាំរបស់សហគមន៍មូលដ្ឋានដើម្បីទប់ទល់ជាមួយគ្រោះមហន្តរាយធម្មជាតិ។ តាមរយៈជំនួយមនុស្សធម៌នេះ យើងខ្ញុំនៅជិតជាមួយនឹងប្រជាជនកម្ពុជា នៅពេលពួកគាត់ឆ្លងកាត់ស្ថានភាពលំបាក។ យើងខ្ញុំសង្ឃឹមថា គម្រោងនេះនឹងពង្រឹងបន្ថែមនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ" ។

តំណាងរបស់កម្មវិធីស្បៀងអាហារពិភពលោក លោកស្រី **Claire CONAN** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលជប៉ុនដែលបានផ្តល់នូវជំនួយដែលមិនអាចកាត់ថ្លៃបាននេះ។ "តាមរយៈជំនួយសប្បុរសនេះ កម្មវិធីស្បៀងអាហារពិភពលោកនិងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានសាងសង់និងបំពាក់ប្រព័ន្ធសម្រាប់មជ្ឈមណ្ឌលជម្លៀសសុវត្ថិភាពទាំង៦នេះ ដើម្បីការពារប្រជាជនក្នុងពេលមានទឹកជំនន់និងគ្រោះ ធម្មជាតិនានា និងជាទីកន្លែងបម្រើផលប្រយោជន៍ចម្រុះសម្រាប់សហគមន៍"។

លោកស្រីបានបញ្ជាក់បន្ថែមថា "ពេលខ្លះ នៅពេលដែលយើងជួបប្រទះគ្រោះលំបាក ការដែលមានទីកន្លែងមួយសម្រាប់ឱ្យយើងអាចជ្រកអាស្រ័យនៅបានដោយអារម្មណ៍សុវត្ថិភាពគឺជារឿងចាំបាច់ណាស់។ យើងខ្ញុំសង្ឃឹមថា មជ្ឈមណ្ឌលទាំងនេះនឹងផ្តល់នូវការការពារបែបនេះ ដល់ប្រជាជនកម្ពុជារាប់ពាន់នាក់"។

លោក **ស្រី ណាល់** ជាមេឃុំ និងជាតំណាងសហគមន៍ បានថ្លែងអំណរគុណដល់រដ្ឋាភិបាលជប៉ុនដែលបានផ្តល់ជំនួយហិរញ្ញវត្ថុ និងស្ថាប័នពីរដែលបានអនុវត្តនិងសម្រេចនូវសមិទ្ធផលដ៏ប្រសើរនេះ គឺកម្មវិធីស្បៀងអាហារពិភពលោកនិងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ តាងនាមសហគមន៍មូលដ្ឋានដែលជាម្ចាស់ពិតប្រាកដនៃមជ្ឈមណ្ឌលទាំងនេះ លោកបានបញ្ជាក់ថា "យើងនឹងថែរក្សាមជ្ឈមណ្ឌលនិងបរិក្ខារទាំងនេះឱ្យបានល្អ ដើម្បីទុកសម្រាប់ឱ្យវាថែរក្សាការពារយើងវិញនៅក្នុងគ្រាលំបាក"។

ក្នុងឆ្នាំ២០១៩ រដ្ឋាភិបាលជប៉ុនបានចូលរួមវិភាគទានចំនួន២,៧លានដុល្លារអាមេរិកដល់កម្មវិធីស្បៀងអាហារពិភពលោក ដើម្បីលើកកម្ពស់ភាពធន់និងរឹងមាំរបស់សហគមន៍នៅកម្ពុជា ក្នុងការប្រឈមជាមួយវិបត្តនានា និងកសាងសមត្ថភាពស្ថាប័ន

សម្រាប់ការត្រៀមលក្ខណៈទប់ទល់ជាមួយគ្រោះអាសន្ន។ ជំនួយគាំទ្រនេះបានបង្កើតនូវសមិទ្ធិផលចំនួនបីគឺ ទី១) ការសាងសង់មជ្ឈមណ្ឌលជម្លៀសសុវត្ថិភាពចំនួន៦ នៅក្នុងខេត្តចំនួន៣ដែលងាយរងគ្រោះដោយទឹកជំនន់ ទី២) ការពង្រឹងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ និង ទី៣) ការលើកកម្ពស់ការចាត់វិធានការទាន់ពេលវេលាតាមរយៈប្រព័ន្ធប្រកាសអាសន្នជាមុន។

ចាប់តាំងពីឆ្នាំ១៩៩៨មក រដ្ឋាភិបាលជប៉ុនគឺជាដៃគូដ៏សំខាន់របស់កម្មវិធីស្បៀងអាហារពិភពលោក ដែលបានចូលរួមវិភាគទានចំនួន២២លានដុល្លារអាមេរិកក្នុងអំឡុងពេល១០ឆ្នាំកន្លងមកនេះ តាមរយៈជំនួយជាសម្ភារៈ (អង្ករ និងត្រីខកំប៉ុង) និងជំនួយជាទឹកប្រាក់ ក៏ដូចជាគាំទ្រក្នុងការលើកកម្ពស់ការត្រៀមខ្លួនទប់ទល់ទៅនឹងគ្រោះអាសន្ន។ នៅដើមឆ្នាំនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាបន្ថែមចំនួន២លានដុល្លារអាមេរិកដល់កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារទឹកជំនន់ទៅលើសន្តិសុខស្បៀងរបស់ក្រុមគ្រួសារ និងសហគមន៍រងគ្រោះដោយសារទឹកជំនន់នៅកម្ពុជា។

---

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោកស្រី ជា ជូ មន្ត្រីផ្នែកទំនាក់ទំនងនិងរបាយការណ៍នៃកម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា តាមរយៈទូរស័ព្ទលេខ៖ +855 78 565 283 ឬ អ៊ីម៉ែល៖ chou.chea@wfp.org